# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៦២ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការសំរាប់គ្រប់គ្រងថវិកា និងត្រួតពិនិត្យគុណភាពសំណង់អាគារសាកលវិទ្យាល័យបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតសាកលវិទ្យាល័យបាត់ដំបង
- បានឃើញសេចក្តីសំរេចលេខ ១៦ សសរ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់សាកលវិទ្យាល័យបាត់ដំបង
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-** បង្កើតអនុគណៈកម្មការចំនួន២ដូចខាងក្រោម សំរាប់ជាជំនួយការឱ្យគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបង ÷

- អនុគណៈកម្មការគ្រប់គ្រងថវិកា និងសម្ភារៈបរិក្ខារសំណង់
- អនុគណៈកម្មការត្រួតពិនិត្យគុណភាពសំណង់អាគារ ។

**ប្រការ ២.-** សមាសភាព និងភារកិច្ចនៃអនុគណៈកម្មការនីមួយៗមានដូចខាងក្រោម ៖

**២.១.-អនុគណៈកម្មការគ្រប់គ្រងថវិកា និងសម្ភារៈបរិក្ខារសំណង់**

ក. សមាសភាព ៖

| | | |
|---|---|---|
| ១- ឯកឧត្តម ប្រាជ្ញ ចន្ទ | អភិបាលខេត្តបាត់ដំបង | ប្រធាន |
| ២- ឯកឧត្តម អ៊ុយ ស៊ុម | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | អនុប្រធាន |
| ៣- ឯកឧត្តម ខាំ អឿន | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៤- ឯកឧត្តម មាស សារឹម | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | សមាជិក |
| ៥- លោក ឡាយ ម៉ូរិន | ប្រធាននាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦- លោក អ៊ុយ លីទ | នាយរងខុទ្ទកាល័យសាលាខេត្តបាត់ដំបង | សមាជិក |
| ៧- លោក នុត ម៉ុណ្ណា | នាយក្រុមហិរញ្ញវត្ថុសាលាខេត្តបាត់ដំបង | សមាជិក |
| ៨- លោក ថុក ម៉ឺនធឿន | អនុប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តបាត់ដំបង | សមាជិក |
| ៩- លោក អ៊ុយ សុធារី | នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តបាត់ដំបង | សមាជិក |
| ១០- លោក ឌួង គឹមសិន | ប្រធានការិយាល័យចំណូលសាលាខេត្តបាត់ដំបង | សមាជិក |
| ១១- លោក ធឿន ហេង | ប្រធានការិយាល័យគណនេយ្យសាលាខេត្តបាត់ដំបង | សមាជិក |

ខ. ភារកិច្ចរបស់អនុគណៈកម្មការ ៖

- គ្រប់គ្រងថវិកា និងសម្ភារៈបរិក្ខារសំណង់សម្រាប់បំរើឱ្យការងារសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបង
- គ្រប់គ្រងថវិកាចំណូលមានបញ្ជីឯកសារអោយបានត្រឹមត្រូវច្បាស់លាស់
- រៀបចំបែបបទចំណាយដើម្បីសុំគោលការណ៍ពិនិត្យ និងសម្រេចពីប្រធានគណៈកម្មការសម្រាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបង
- គ្រប់គ្រងបញ្ជីចំណាយ និង ខិតខំត្បិតត្បៀតសន្សំសំចៃចំពោះគម្រោងចំណាយណាដែលពុំចាំបាច់
- គ្រប់គ្រងសម្ភារៈបរិក្ខារសំណង់ ដោយធ្វើការទទួល និងបញ្ចេញបញ្ចូលមានលិខិតស្នាមត្រឹមត្រូវច្បាស់លាស់
- ធ្វើរបាយការណ៍ទៀងទាត់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ រហូតដល់បញ្ចប់គម្រោងសាងសង់អាគារសាកលវិទ្យាល័យជាស្ថាពរ ។

**២.២.- អនុគណៈកម្មការត្រួតពិនិត្យគុណភាពសំណង់អាគារ**

ក. សមាសភាព ៖

| | | |
|---|---|---|
| ១- ឯកឧត្តម ម៉ម ស្វាធារណា | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | ប្រធាន |
| ២- ឯកឧត្តម អ៊ុយ ស៊ុម | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | អនុប្រធាន |
| ៣- ឯកឧត្តម អ៊ុក ខឿ | អភិបាលរងខេត្តបាត់ដំបង | អនុប្រធាន |

៤- ឯកឧត្តម ចាន់ ណារ៉េត សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម សមាជិក

៥- ឯកឧត្តម ហ៊ុយ ណារ៉ា អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៦- ឯកឧត្តម ឈាង ភាន់ឌី ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង សមាជិក

៧- លោក ម៉ីត់ ខយ អគ្គនាយករង នៃអគ្គនាយកដ្ឋានឧត្តមសិក្សា
ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៨- លោក អ៊ុយ រី អភិបាលស្រុកបាត់ដំបង សមាជិក

៩- លោក យូ ទីរៈ អនុប្រធាននាយកដ្ឋានឧត្តមសិក្សា
ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១០- លោក ខួន វេនៈ ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់
និងសុរិយោដីខេត្តបាត់ដំបង សមាជិក

១១- លោក ឆៅ ប្រុំ នាយខុទ្ទកាល័យសាលាខេត្តបាត់ដំបង សមាជិក

១២- លោក គុប តាន់លាង ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង សមាជិក

១៣- លោក ម៉ៅ ម៉ើ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង សមាជិក

១៤- លោក ខាន់ ម៉ាណោរ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបាត់ដំបង សមាជិក

១៥- លោកឧកញ៉ា ទ្រីក ជួរ អ្នកទទួលម៉ៅការសាងសង់សាកលវិទ្យាល័យ សមាជិក

១៦- លោក សៀង សង់ងម ទីប្រឹក្សាអភិបាលខេត្តបាត់ដំបង សមាជិក

១៧- លោក ចេង ខ្មែ អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដីខេត្តបាត់ដំបង សមាជិក

១៨- លោក ពាន ណារិទ្ធ អគ្គលេខាធិការសាលាខេត្តបាត់ដំបង សមាជិក

១៩- លោក នាង ច័ន្ទថាវី អគ្គលេខាធិការរងសាលាខេត្តបាត់ដំបង សមាជិក

២០- លោក ឈឹម សំណាង ប្រធានការិយាល័យកិច្ចការសុរិយោដីខេត្តបាត់ដំបង សមាជិក

ខ. ភារកិច្ចរបស់អនុគណៈកម្មការ :

- ធ្វើការត្រួតពិនិត្យការងារសាងសង់សំណង់អាគារសាកលវិទ្យាល័យបាត់ដំបង ឱ្យបានសមស្រប តាមបទដ្ឋានបច្ចេកទេសសំណង់ និងគំរោងប្លង់ គ្រឿងបង្គុំសំណង់ ដែលបានសម្រេចជាផ្លូវការរួចហើយ
- ត្រួតពិនិត្យ និងជំរុញឱ្យអនុវត្តតាមប្រតិទិនការងារនៃដំណើរការគម្រោងសាងសង់អាគារឱ្យទាន់ពេលវេលា
- ត្រួតពិនិត្យជាប្រចាំលើការងារបច្ចេកទេសនៃការសាងសង់ ដើម្បីធានាឱ្យបាននូវគុណភាពសំណង់រឹងមាំ យូរអង្វែងប្រកបដោយរចនាបទល្អ

- ករណីពិនិត្យឃើញថាមានភាពមិនប្រក្រតីលើការងារសាងសង់ អនុគណៈកម្មការត្រូវធ្វើការប្រជុំជាបន្ទាន់ដើម្បីមានវិធានការដោះស្រាយ
- ធ្វើរបាយការណ៍អំពីល្បឿននៃការសាងសង់ ជូនគណៈកម្មការសម្រាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបងដើម្បីជូនជ្រាប និងណែនាំបន្ត
- ប្រធានអនុគណៈកម្មការត្រូវកោះប្រជុំអនុប្រធាន និងសមាជិកគណៈកម្មការឱ្យបានជាប្រចាំដើម្បីកំណត់ការទទួលខុសត្រូវក្នុងការអនុវត្តការងាររបស់ខ្លួន ។

**ប្រការ ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង-សាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ព្រមទាំងអភិបាលខេត្តពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៧

ជ. នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចចែងក្នុងប្រការ ៣
- ឯកសារ-កាលប្បវត្តិ